# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ អ៊ឹម សារឿន ភេទស្រី អាយុ៥១ឆ្នាំ
## រស់ភូមិធ្នង់រលើង ឃុំលាយបូរ ស្រុកធ្នង់រលើង ខេត្តតាកែវ
## នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៥
## សម្ភាសន៍ដោយៈ ញាណ សុជាតិ

*រឿនៈ សួរពីជំនាន់ប៉ុល ពត កាលពីឆ្នាំ៧៥ ។ ពីឆ្នាំ ៧៥ បែកពីតាកែវមកដល់ឆ្នាំ៧៩ ។ ពី៧៥ ខ្ញុំនៅតាកែវ នៅផ្សារតាកែវហ្នឹងបែកពីឆ្នាំ៧៥ ទៅវត្តចម្បារ ចូលទៅចម្បារ គ្រួសារខ្ញុំធ្វើទាហាន ចេញពីហ្នឹងមកទៅចម្បារជួបជុំគ្នាទាំងអស់គ្នា នៅចម្បារហ្នឹង ចេញមកដល់វត្តចម្បារ រយៈពេល១០ថ្ងៃ ។ រយៈពេល១០ថ្ងៃ អោយបែក បែកចេញពីចម្បារមកចូលនៅតាមភូមិតាមគេថាអោយមានបងប្អូន មានចៅអី អត់មានបានអី មកហូបនោះចេះតែរកបងប្អូនអញ្ចឹងទៅ អោយស្រូវអោយអង្ករអីមកហូប មានរបស់របរបន្តិចបន្តួចហ្នឹង ខោអាវហ្នឹង លុយអត់ចាយទេ លុយ មានខោអាវអីហ្នឹង ដល់តែយូរយើងដាក់មានមាសបន្តិចបន្តួចអីអញ្ចឹង ទុកអញ្ចឹងទៅ ដល់តែហើយមកនៅ៧៦, ៧៦ ចុះមកទាំងអស់គ្នា មកនៅភូមិហ្នឹង មកពីចម្បារមកនៅភូមិហ្នឹង ព្រោះនៅក្នុងអណ្តូងហ្នឹង ដល់តែហើយគាត់យកទៅកងគ្រួសារខ្ញុំហ្នឹង ។ ខ្ញុំទៅកង ខ្ញុំទៅកងធ្វើប្រឡាយ ទំនប់អីអញ្ចឹងទៅ គាត់ទៅកងពីលើ កាប់គាស់ព្រៃលើហ្នឹង ស្រាប់តែបាត់រហូតអញ្ចឹងទៅ គាត់ធ្វើទាហាន គេសួរគាត់ប្រាប់ថា គាត់ធ្វើទាហានកាលពីជំនាន់លន់ នល់ គាត់ទាហានខាង១០៥ខាងកាន់កាំភ្លើងធំនោះ ថាអូច្នោងដាក់ប៉ុន្មានគ្រាប់ គ្រួសារខ្ញុំគាត់ត្រង់ ហើយខ្ញុំបាត់ដំណឹងរហូត ហើយចុះចេះតែ សួរដំណឹងអញ្ចឹងទៅ តែបាត់ បាត់រហូត វាមិនឃើញមកវិញ ។*

*រឿនៈ ដំបូង ខ្ញុំហ្នឹង ។*

*រឿនៈ ឈ្មោះ អ៊ឹម សារឿន ។*

*រឿនៈ ខ្ញុំកើតឆ្នាំ ១៩៥៦ ។*

*រឿនៈ ចា៎!*

រឿនៈ ៥០ ជាងហើយ ។

រឿនៈ ៥០ អេ ៥១ទេ ។

រឿនៈ ១៩៥៦ ។

រឿនៈ ចាំ ៥៦ ឆ្នាំ ១៩៥៦ ។

រឿនៈ ស្រុកកំណើតនៅលាយបូរ ត្រាំកក់ ស្រុកត្រាំកក់ ។

រឿនៈ ពីដំបូងនៅភូមិពីរល្វែង ។

រឿនៈ ចាំ ប៉ុន្តែ ឥលូវហ្នឹង បច្ចុប្បន្ន ដាក់ភូមិ ធ្នង់រលើង ។

រឿនៈ ឃុំលាយបូរ ។

រឿនៈ តាកែវហ្នឹង ។

រឿនៈ ភូមិធ្នង់រលើង ។

រឿនៈ ឃុំលាយបូរ ស្រុកត្រាំកក់ ។

រឿនៈ ដូរ កាលបែកពីជំនាន់ប៉ុល ពតមក ។

រឿនៈ ចាំ ។

រឿនៈ អត់ដូរទេ ទើបតែបែកមកគេដាក់ដូរ ខាងលិចហ្នឹង អគ្គនាយណ៍ លិចហ្នឹងភូមិធ្នង់រលើង

រឿនៈ អេ ចាស់ៗពីដើម ចេះតែហៅមកពីដើម គេមានធ្នង់រលើងហ្នឹង ប៉ុន្តែនៅខាងត្បូងថ្នល់ ។

រឿនៈ ចាំ ខាងត្បូង ។

រឿនៈ ប៉ុន្តែឥលូវខាងត្បូងថ្នល់ដាក់ត្រពាំងព្រីង ។

រឿនៈ មកខាងជើង ដាក់ធ្នង់រលើង ។

រឿនៈ ពីរល្វែង ពីដើម ពីរល្វែង ។

រឿនៈ ខ្ញុំកាលពីជំនាន់ ពីបែកទៅកាលពី ៧៤, ៧៣ហ្នឹង ខ្ញុំរៀនដល់ថ្នាក់ទីប៉ុន្មាន រៀនបាន បន្តិចហ្នឹងចាំមើល កាលហ្នឹងទី៥, ទី៦ គេនោះមិនទាន់ទី៧ដងហ្នឹង ដំបូងទី៥, ទី១០, ទី ១១, ទី ១២ អីអញ្ចឹងទៅ៨, ទី៩ហ្នឹង ទី៨, ទី៩ហ្នឹង ខ្ញុំចូលទី៨ហ្នឹង ។

រឿនៈ ឈប់ទី៨ហ្នឹង ។

រឿនៈ ឆ្នាំ ទី៨ ពី១៩៧៣ អុន ។

រឿនៈ ចាំ! ១៩៧៣ហ្នឹងយើងបែកពីនេះ រត់ទៅអញ្ចឹង ទៅនៅចូល ទៅ បារាយណ៍ទៅអីអញ្ចឹង ទំរាំតែចូលទៅដល់ទីរួមខេត្ត ទៅនៅឃុំបារាយណ៍ នៅភូមិថាវ ។

រឿនៈ វា រត់ទៅ វាអត់មានលុយកាក់ទេ ឪពុកម្តាយក្រអញ្ចឹង ។

រឿនៈ សង្គ្រាមអាហ្នឹង សង្គ្រាមហើយ ចូលទៅដល់នោះ រកផ្ទះអត់នៅ អត់មានផ្ទះនៅទេ ។

រឿនៈ សាលានៅលាយបូរនេះ បិទហើយ ចូលទៅសាលានៅជាស៊ឹម ឥលូវនៅសាលា ជាស៊ឹម នៅតាកែវ នៅបើកទាហាន ។

រឿនៈ លាយបូរ ។

រឿនៈ ១៩៧៣ ហ្នឹង រត់ទៅហ្នឹង ។

រឿនៈ ខ្ញុំឈប់ ខ្ញុំឈប់ ។

រឿនៈ ប៉ុន្តែប្អូន ប្អូននៅរៀន ខ្ញុំឈប់ពីឆ្នាំ ១៩៧៣ ហ្នឹងតែម្តង ។

រឿនៈ បាតុកម្មកាលឆ្នាំទម្លាក់សម្តេច កាលពីឆ្នាំ១៩៧០ ហ្នឹងបាតុកម្ម ពីអង្គតាសោមមក ។

រឿនៈ បាតុកម្មនៅអង្គតាសោមមក រត់មកពីអង្គតាសោម ខ្ញុំនៅតូច ខ្ញុំនៅផ្ទះទេណា ឪពុកម្តាយ ខ្ញុំទៅលក់ជ្រូក ពីដើមទៅលក់ស្ពៃ លក់ជ្រូកនៅអង្គតាសោមហ្នឹង គាត់រត់មកបាតុកម្ម កាំភ្លើងអី គេស្រែកមានឡានមានរម៉កអី តាមមកដល់ហ្នឹង អញ្ចឹងមក ដល់ទៅតាកែវ ទៀត ។

រឿនៈ បំផុសបំផុល អោយទៅ ប៉ុន្តែខ្ញុំនៅក្មេង ខ្ញុំនៅកុមារ ខ្ញុំ ។

រឿនៈ អត់ទេ ។

រឿនៈ តែចាស់ៗគេរត់មក ស្លាប់ច្រើនៗ កុំទៅៗគាត់បេះ ហើយកាលហ្នឹងបាញ់ៗផ្សេងអី ។

រឿនៈ បេះតែក្រាបទៅ ខ្ញុំទៅពួននៅហ្នឹង អង្គភូមិ នៅចេតិយហ្នឹង ។

រឿនៈ ដល់តែសម្លាប់វៀតណាម សម្លាប់អីទៅ តែ៧០ហ្នឹងសម្លាប់វៀតណាម នៅមកពីតាកែវ តែនេះបាតុកម្មអង្គតាសោមនេះ ស្លាប់ច្រើន ។

រឿនៈ ពីដើម គាត់លក់ជ្រូក លក់ស្ពៃ ជីអីហ្នឹង គាត់រកស៊ីចិញ្ចឹមកូន ជាផ្ទះអញ្ចឹងទៅណា គាត់នៅក្មេងរត់រម៉កអីអញ្ចឹងអីអញ្ចឹង ។

រឿនៈ ខ្ញុំរៀបការឆ្នាំ១៩៧៥ ។

រឿនៈ ១៩៧៥ អាយុ១៨ ។

រឿនៈ ខ្ញុំចាំតែខែពិសាខ មិនដឹងជាខែប៉ុន្មានទេ ភ្លេចបាត់ហើយនេះ ។

រឿនៈ ពិសាខ ។

រឿនៈ កាលចូលឆ្នាំ ប៉ុន្តែខ្ញុំការកាលពីខែ ពិសាខ ។

រឿនៈ ខែពិសាខ ។

រឿនៈ ១៩៧៥ ។

រឿនៈ មិនទាន់បែកភ្នំពេញទេ ។

រឿនៈ ខ្ញុំមិនមែនការ ១៩៧៥ ការ១៩៧៤ ។

រឿនៈ ១៩៧៤ ខែពិសាខ ១៩៧៥បែក ។

រឿនៈ ចាំ បែកចូលឆ្នាំ ។

រឿនៈ បែកខែចែត្រ ចូលឆ្នាំ អាហ្នឹងកាលពី១៩៧៤ ។

រឿនៈ ចាំ ១៩៧៥បែក ។

រឿនៈ ធ្វើទាហាន ។

រឿនៈ ចាំ ។

រឿនៈ គាត់ពីមុនហ្នឹងមក គាត់ធ្វើកាលពីកូនក្មេង គាត់ធ្វើតាំងពីអាយុ១៨ ។

រឿនៈ មុនធ្វើ១៧ ១៨ បងប្អូន មាគាត់ យកទៅធ្វើទាហាន គាត់កំព្រាដែរ ។

រឿនៈ នៅព្រៃផ្គាវ ។

រឿនៈ ទីរួមខេត្ត ។

រឿនៈ ត្រាំង ។

រឿនៈ ត្រាំង កាលហ្នឹង ឈ្មោះ គាត់ អ៊ុយ មុត ។

រឿនៈ ចាំ! នេះ ប្អូនតានេះដីដូនមួយ ។

រឿនៈ ហើយកាលហ្នឹង គាត់នៅជាមួយឪពុកគាត់ហ្នឹង ហើយ អ៊ុយហ្នឹង ឪពុកគាត់ហ្នឹង ដាក់ឈ្មោះអ៊ុយ មុខរហូត ។

រឿនៈ កាលហ្នឹង គាត់នៅសាលាកន្លែងយើងគរុកោសល្យហ្នឹង កន្លែងគ្រូគរុកោសល្យហ្នឹង ។

រឿនៈ តាកែវហ្នឹង កាលហ្នឹង ដាក់កាំភ្លើងធំ កន្លែងគរុកោសល្យហ្នឹង ។

រឿនៈ ហៅ១០៥ ចាំ គាត់កាំភ្លើងធំ គេហៅ ១០៥ ។

រឿនៈ ហ្នឹង ។

រឿនៈ គាត់អត់មានទៅមុខ គាត់គ្រាន់តែនៅផ្ទាង ហើយ ពេលអញ្ចឹង ។

រឿនៈ ក្រោយគេឡើងទៅឆ្ងាយអញ្ចឹង គេអោយអូស កាំភ្លើងហ្នឹង មកតាមអញ្ចឹងណា ។

រឿនៈ អញ្ចឹងទៅជួយ ជំនួយ ជួយអញ្ចឹងទៅណា ។

រឿនៈ ជាប់ផ្ទាងអញ្ចឹងជួនណា ផ្ទាងត្រូវគេអញ្ចឹង ជួនណាចំត្រូវគេឯងអីវ៉ាន់ក៏មានដែរណា ។

រឿនៈ នៅក្រោយទេ អត់មានទៅវាយទេ ។

រឿនៈ មកផ្ទះនៅតាកែវអោះ ។

រឿនៈ ការនៅតាកែវ នៅផ្សារហ្នឹង នៅជាប់មហោស្រពហ្នឹង ខាងលិចមហោស្រពហ្នឹង ខ្ញុំនៅហ្នឹងតើ ជិត មន្ទីរឃោសនាការហ្នឹង ។

រឿនៈ ផ្ទះពូ ។

រឿនៈ ពូធ្វើគ្រូ ឥលូវគេយកយាយៗ គាត់និយាយថា គេយកទៅចោលហ្នឹង មាហ្នឹង ។

រឿនៈ ទៅនៅជាមួយមាហ្នឹងតើ គាត់មានផ្ទះគាត់វែង ឃើញតែបងប្អូនទៅនៅហ្នឹង ។

រឿនៈ រត់ទៅ ទៅនៅជាមួយគាត់ ខ្ញុំការផ្ទះគាត់ ។

រឿនៈ គាត់ជួយចិញ្ចឹមជួយអី ហើយឪពុកខ្ញុំរត់រម៉កចូលទៅ ។

រឿនៈ ចាំ ដំបូងគាត់រកស៊ីជួយជ្រូក ធ្វើស្រែ នៅយើងនេះហ្នឹង ទៅដល់ពីនេះ ទៅ គាត់រត់ចូលទៅ គាត់ទៅរត់រម៉ក នៅថាវ ទីរួមខេត្តហ្នឹង គាត់រត់រម៉ក ហើយដល់តែហើយដល់តែពេលតឹង គេអោយចូលធ្វើទាហាន គាត់ចូលធ្វើទាហានៗទៀត ទាហានចាស់ៗអោយនៅយាមក្រោយ ក្មេងៗៗ គេយកទៅវាយមុខ ។

រឿនៈ យាមត្រឹម បន្ទាយអូចំបក់ហ្នឹង គេហៅថា កុម្មង់ដូរៗហ្នឹង ។

រឿនៈ ហើយកាលហ្នឹង អាមេរិកាំងមកធ្វើផ្ទះថែក ធ្វើផ្ទះថែកអោយបន្ទាយ ។

រឿនៈ ធ្វើផ្ទះអោយ ។

រឿនៈ អោយចាស់ៗ កុម្មង់ដូ ឪខ្ញុំឥវ៉ាន់ហ្នឹង ។

រឿនៈ ថែកតែឥវ៉ាន់ហ្នឹង បានមួយបន្ទប់ មួយបន្ទប់ ដែរហ្នឹង ។

រឿនៈ បើកអគ្គរអោយហូប តើអូនកាលហ្នឹង កូនច្រើន ។

រឿនៈ  ទាហានជំនាន់លន់  នល់ចាស់ៗហ្នឹង  សុទ្ធតែទាហានដែរ  ប៉ុន្តែ  ទាហានមកភូមិក្រោយ ក្មេងៗៗឡើងវាយមុខហើយហ្នឹង ។

រឿនៈ  ប៉ុល  ពតចូលមក ។

រឿនៈ  ចា៎  កាលហ្នឹងមានបន្ទាយ  នៅបន្ទាយ  នៅសាលាឃុំយើង ។

រឿនៈ  លាយបូរហ្នឹង  បន្ទាយទាហាន ។

រឿនៈ  បន្ទាយទាហាន  ខាងលន់  នល់  យើងហ្នឹង  ពួក៩៨ ។

រឿនៈ  ពួក១៩៩៨  គេនៅហៅពួក  របបកម្ពុជាក្រោម ។

រឿនៈ  ហើយកាលហ្នឹងបន្ទាយទាហាន  មេទាហាននៅហ្នឹងគេហៅលោក  សាញ់ ។

រឿនៈ  លោក  សាញ់  ហើយវាយពួកប៉ុល  ពត  មកព័ទ្ធវាយបែកទៅ  បានជម្លៀសរត់ទៅហ្នឹង ។

រឿនៈ  ទៅទាំងអស់ ។

រឿនៈ  បែកបន្ទាយលោកសាញ់ហ្នឹង  ។

រឿនៈ  ទៅ  បែកបន្ទាយលោកសាញ់នៅបន្ទាយមួយទៀត  នៅសាច់ជ្រុំ  នៅអត់បែកទេ  ប៉ុន្តែ កន្លែងនេះវាបែកបន្ទាយនេះ  វារត់ទៅអញ្ចឹងទៅៗខ្លះទៅ  លិចគេកៀរបានទៅ  គេបក់ដៃ ខ្ញុំឥវ៉ាន់ទៅ  ដើមត្នោតហ្នឹង  ដឹកគោហើយគេបក់ដៃអញ្ចឹងទៅ  ហើយគ្នា  រត់ទៅលិចអញ្ចឹង គេកៀរបាន ។

រឿនៈ  ខ្ញុំបេះតែរត់ទៅកើត  ព្រោះអី  ឪពុកម្ដាយខ្ញុំទៅកើតហួសហើយ ។

រឿនៈ  ខ្ញុំមកដឹកគោ ។

រឿនៈ  ចា៎!  អ្នកទៅលិច  ទៅលិចទៅ  អ្នកទៅកើត  ទៅកើត  ខ្ញុំបេះតែរត់ទៅកើតទៅ  ព្រោះអី តាមឪពុកម្ដាយ  យាយទៅលិច  មីងទៅលិចណា  តែខ្ញុំតាមឪពុកម្ដាយ  ព្រោះអីគាត់ អាប្អូនតូចៗ  គាត់ដឹកដៃទៅមុន  អោយខ្ញុំដឹកគោ  ខ្ញុំបងគេ  បងគេបង្អស់ដឹកគោរត់ៗ ដឹកគោរត់  អើយគេបាញ់  គេដេ្វងមក  ដាក់ជុំវិញអស់ហើយ  លូនអញ្ចឹងទៅ  ហើយលឺ ដំណឹងទៅលិចថាងាប់ហើយៗសក់វែងកាលហ្នឹងស្លាប់មែន  ស្លាប់គេសក់វែង  ហើយគាត់ សន្មប់ថាខ្ញុំស្លាប់  ។

រឿនៈ  អ្នកគេនៅស្រុកលើ  គាត់នៅភូមិលិចនោះ ។

រឿនៈ  យាយខ្ញុំបង្កើតហ្នឹង ។

រឿនៈ  យាយមីងហ្នឹងប្រចាំ អ្នកបែកពីបន្ទាយ រត់មកបានត្រូវអញ្ចឹង ។

រឿនៈ  ខ្ញុំរត់ទៅកើត បែកមក មកជួបនេះ៧៥ហ្នឹង ជួបហ្នឹង ជួបគាត់ហ្នឹង គេអត់អោយមករកគ្នាទៀតអូន ។

រឿនៈ  មូលដ្ឋានគេអត់អោយរកអ្នក១៧ទេ ហៅ១៧ ។

រឿនៈ  ទៅ ទាំងអស់ ។

រឿនៈ  មិនទាន់ការទេ ខ្ញុំកាលហ្នឹងអត់ទាន់ការទេ ខ្ញុំ និងបងប្អូនខ្ញុំ ៦នាក់ ។

រឿនៈ  ទីមួយ ។

រឿនៈ  បងគេទីមួយ ខ្ញុំហ្នឹង ធំជាងគេ ។

រឿនៈ  ពៅគេនៅតូច ហ្នឹង ។

រឿនៈ  ៦នាក់ ពៅគេនៅតូច ។

រឿនៈ  ប្រុស ៥ ស្រីតែខ្ញុំមួយ ។

រឿនៈ  ទី១ ហើយខ្ញុំយ៉ាប់ ពិបាកជាងគេ បានឈប់ហ្នឹង ។

រឿនៈ  ចាំ ។

រឿនៈ  នៅទាំងអស់ ។

រឿនៈ  ចាំ បើជិនាន់ប៉ុល ពត ប្អូនៗនៅតូច ។

រឿនៈ  ធំ តែខ្ញុំ អាមួយនោះ នៅកុមារដែរ កុមា បំរុងហ្នឹងគេអោយទៅនៅទំនប់លោកៗ ហើយទំនប់លោក ភ្នំលិចហ្នឹងម្តុំសិរីសោភ័ណ បូជង់ហ្នឹង ទំនប់លោកៗហ្នឹង អាហ្នឹងកុមារ កុមារបំរុះ ។

រឿនៈ  ហើយមួយទៀត កុមារ ហ្នឹង បំរុង គេអោយនៅព្រៃលើ ។

រឿនៈ  ហើយខ្ញុំហ្នឹងសុទ្ធតែនៅកងអស់ហើយបីនាក់នៅតូចៗ នៅជាមួយយាយ ហើយដល់តែបន្ទាប់ទៀត អាមួយទៀតផ្ទះនៅនេះ គេយកទៅកងទៀត ដល់តែហើយស្រាប់តែវានៅតូចវាវង្វេងអញ្ចឹង វារត់មកតាមគេមក មេកងអី គេតាមមកអញ្ចឹងគេចូលវត្តលាយបូរនេះយប់ អេគេថាថ្ងៃរះ ថ្ងៃលិចហ្នឹង គេថាថ្ងៃរះមកពីកើត យប់ កើតដល់ផ្ទះយប់ ហើយយំ ពីយំមកអញ្ចឹង ឪពុកថាហើយចុះមកអញ្ចឹង ខ្លាចគេតាមមកយកវាយចោល

ដល់តែព្រឹកឡើង គេតាមមក គាត់ប្រាប់ថា អូនអើយ កុំវាយវាអីព្រោះអាហ្នឹង វាមិនសូវដឹងអីទេ វាឆ្លុតជ្រូក កុហកថាឆ្លុតជ្រូកតើ ។

រឿនៈ ហើយទៅសុំ ប្រធានភូមិ ទៅសុំមេឃុំ តែកាលហ្នឹងតានៅ តានៅ ។

រឿនៈ តានៅ មេឃុំសុំតានៅ ដល់តែហើយអញ្ចឹង សុំគាត់អញ្ចឹង សុំប្រធានភូមិ តឹកកុយអញ្ចឹងទៅ គេអោយសប់ស្នប់ អាកនហ្នឹង ឆ្លុតជ្រូកតើសប់ស្នប់ សប់អោយគេវាយ ដែកនៅផ្ទះរាល់ថ្ងៃទៅ ទៅនៅជាមួយយាយទៅនៅផ្ទះ ទៅនៅជាមួយយាយ គេអោយធ្វើការដែរ ប៉ុន្តែ នៅជិតៗ ។

រឿនៈ ហើយអាពីរនោះ នៅជាមួយយាយអញ្ចឹង យាយគាត់ដើរបោសអាចម៍ វែងអាចម៍អញ្ចឹងនៅជាមួយយាយ ។

រឿនៈ តូចៗធ្វើបន្តិចគេយកដាក់កងអញ្ចឹងទៅ ប៉ុនតែកងអោយយាយ យាយមើល មិនមែនអោយយាយហ្នឹង មើលទេណា ។

រឿនៈ ពេលយប់បានវាអោយមកផ្ទះ ។

រឿនៈ បែកតាកែវហើយទៅកងព្រៃលើ ។

រឿនៈ ហើយ បែកតាកែវ ខ្ញុំទៅធ្វើនំលក់ហ្នឹង ។

រឿនៈ ធ្វើនំគ្រូច នំអាកោរអី ខ្ញុំធ្វើលក់នៅផ្សារ ដាក់ថាសយកទៅលក់ ។

រឿនៈ បែកហ្នឹង គេវាយតាកែវហ្នឹង វាយចូលទៅ វាយចូលទៅតាមផ្លូវ វត្តជីទាលចូល ពីលិចហ្នឹង អូរចំបក់ហ្នឹង ផ្ទោងមួយយប់ហ្នឹង គ្មានបានដេកទេ ។

រឿនៈ អាធ្វើហើយនោះ ឡើងធ្វើយកទៅលក់ ហើយព្រលឹមឡើងមិនស្វាត់ ស្វាត់ មិនគ្រលៀតដាក់លក់ ។

រឿនៈ ហើយមកទល់ពេលបាញ់ខ្លាំងអញ្ចឹង បែកឪពុកម្តាយ ទៀត ខ្ញុំឪពុកម្តាយចេញមកមុនចេញមកលក់នំ ។

រឿនៈ គាត់ចេញមកលិចមក គេថាអោយចេញមក ចេញមក ។

រឿនៈ ហើយខ្ញុំមកក្រោយគាត់ បែក ចេញមក ចេញមកបែកទៀត គ្រួសារខ្ញុំក៏បែកដែរ ។

រឿនៈ មកតែខ្ញុំទេ ។

រឿនៈ គាត់នៅបន្ទាយ នៅបន្ទាយ ។

រឿនៈ ចេញមកដល់ថ្នល់រទេះភ្លើង មិនជួបគ្នា ជួបគ្រួសារខ្ញុំ គាត់ស្ទៀកពាក់ទាហានមក មកដល់ជួបឪពុកខ្ញុំ មកដល់ហ្នឹងដែរ ។

រឿនៈ គាត់អោយផ្លាស់សារ៉ុង ស្រាតខោទាហានចេញ ។

រឿនៈ ខ្ញុំស្ទៀកសារ៉ុង ពាក់អាវស ។

រឿនៈ ឪពុកខ្ញុំហ្នឹង អោយផ្លាស់ គ្រួសារខ្ញុំ គាត់ធ្វើទាហាន ។

រឿនៈ អោយកូនប្រសារផ្លាស់ខោចេញទៅ ស្ទៀកសារ៉ុង ហើយអោយពាក់អាវសទៅ ។

រឿនៈ គាត់ស្ទៀកពាក់ចេញមក ។

រឿនៈ ហើយដល់តែមកដល់ហ្នឹង គេចង គេថាអ្នករដ្ឋការ ដើរលើថ្នល់ អ្នកស៊ីវិលចុះមកក្រោម ។

រឿនៈ គេប្រកាស ហើយគេចង គេបោចបន្ទាបស្រ្កាបអូន បន្ទាបស្រ្កាបហ្នឹងហើយ និងអ្នកពីក្រោយអីចងតើ ហើយអ្នកត្រង់ បេះតែដើរហើយ ហើយដល់តែហើយ ខ្ញុំរត់ពីក្រោយទៅបន្ទាប់គ្រួសារខ្ញុំអោយឡើងលើវិញ ចុះក្រោមវិញ លូង់អញ្ចឹងបានទៅនៅចម្បារបានជួបជុំគ្នា បានមកនៅកងដល់តែហើយ នៅប្រាប់គេទៀតថាខ្ញុំកាន់កាំភ្លើង ធំបានគេយក ។

រឿនៈ សួរ សួរថា ប្តីរត់រម៉ក ។

រឿនៈ ហើយដល់តែសួរ គ្រួសារ គ្រួសារខ្ញុំត្រង់អាំ ថា ខ្ញុំធ្វើទាហាន គេថា ។

រឿនៈ យកមកអញ្ចឹង គេអោយមកភូមិ មកភូមិអញ្ចឹង គេហៅទៅកង ។

រឿនៈ ភូមិផ្នង់រលើងហ្នឹង ។

រឿនៈ ចាំ ។

រឿនៈ ទៅវត្តចំបារនៅ១០ថ្ងៃ ។

រឿនៈ ចាំ ។

រឿនៈ គេវេចបាយសំនុំ យកទៅចែក បាយសំនុំ ដូចគ្រួសារខ្ញុំហ្នឹង ៨នាក់អញ្ចឹង គេអោយ ពីរសំនុំអញ្ចឹង ទាំងកូនប្រសារអី បង្កើតហ្នឹង ។

រឿនៈ ហើយចុះមិនគ្រាន់ក៏ថាគ្រាន់ដែរ ម៉េចនឹងហ៊ាន ។

រឿនៈ គេតាមដែរហ្នឹង តាម ខ្ញុំអត់ហ៊ានមាត់ទេ បងប្អូនអ្នកចាស់ អ្នកចាស់ គេយកបាយ យកបាយមកអោយ វេចសំនុំដាក់ត្នោត ។

វឿនៈ ចេះតែកុំអោយមាត់ កុំអោយនិយាយអីអញ្ចឹងទៅជីដូន ជីដូនមួយ ហើយពោះមួយផង ពោះខាងម្ដាយ គាត់ថាបងឯងកុំមាត់ អោយអីហូបហ្នឹងកុំមាត់ អញ្ចឹងទៅណាប្រាប់កូនក្មួយអញ្ចឹងទៅ ហើយអត់ហ៊ានមាត់ទេ ។

វឿនៈ នៅស្ងៀម នៅអត់មានធ្វើអីទេ នៅក្នុងវត្តហ្នឹង អោយនៅមួយដុំអញ្ចឹងទៅ អត់មានធ្វើអីទេ អោយជម្លៀសមកតាមភូមិបានប្រើ ទៅបន្ទាយ ទៅគាស់ព្រៃ លើកទំនប់អី អញ្ចឹងទៅ ។

វឿនៈ គេអោយមកតាមភូមិ ប្រកាសថា អោយមកស្រុកទេសនៅឯណាអោយទៅហ្នឹងទៅ ។

វឿនៈ ទៅតាមភូមិទៅណា ។

វឿនៈ អោយមកតាមជនបទយើង ស្រុកទេសនៅឯណា អោយមកហ្នឹងទៅ ។

វឿនៈ ចា៎ ឪពុកម្ដាយនាំមកហ្នឹង ។

វឿនៈ មកទាំងអស់គ្នា ។

វឿនៈ ចា៎ បងប្អូនទាំងគ្រួសារខ្ញុំ មកទៀត ។

វឿនៈ មកបានគេយកទៅកងឯលើ បែកទៅកង ហ្នឹងទៅ វាយទាល់តែធ្លាក់ឈាម ។

វឿនៈ ឪពុកខ្ញុំ កាន់កងនង្គ័លគាត់ ។

វឿនៈ ចា៎ ម៉ែខាងធ្វើដី វែកដី ។

វឿនៈ វែកដី បុកអាចម៍ លាយអាចម៍ហ្នឹង ។

វឿនៈ អត់ទេ គាត់ថា គាត់រត់រម៉ក ។

វឿនៈ គេអត់ដឹងរហូតអញ្ចឹងមក ។

វឿនៈ បើដឹងបាននៅអេ បងប្អូនគាត់ មើលនៅទាំងអស់នេះតែឥវ៉ាន់ ។

វឿនៈ កុម្មង់ដូ ទាហានចាស់ ចាស់ គេហៅទាហានកុម្មង់ដូ ។

វឿនៈ កាលហ្នឹង កាន់អឹមសី ហើយនិងអាកាំភ្លើងអី កាលប៊ឹនគេនោះ ។

វឿនៈ ចា៎ នៅក្រោយនោះ ជួនណាតែឥវ៉ាន់តើ អូន មានគ្រប់មុខដែរហ្នឹង បុិនតែយាមត្រឹម ថ្នល់រទេះភ្លើងហ្នឹង គេហៅទាហានចាស់ កុម្មង់ដូរៗ ។

វឿនៈ នៅក្នុងភូមិហ្នឹង ជួរទៅអញ្ចឹងទៅ ទៅតាមភូមិអញ្ចឹង កងជុំវិញ ឃុំលាយបូរអញ្ចឹងទៅណា ។

រឿនៈ ព្រៃលើអញ្ចឹងទៅ មួយឃុំលាយបូរ តាមគេដាក់វាយឯណា ហៅទៅអញ្ចឹងទៅ យប់អីអញ្ចឹងទៅ ។

រឿនៈ ភ្នូរនគ្គ័ល មកនៅភូមិលាយបូរ មកនៅកងនគ្គ័ល ។

រឿនៈ ទៅ ទៅ នៅកង អត់មាន នៅផ្ទះ នៅកង ។

រឿនៈ អត់ទេ ខ្ញុំក៏នៅកងដែរ ។

រឿនៈ បែកទាំងអស់ ។

រឿនៈ ប្រាំនាក់ អាបី ពីរនាក់ទៅកង ខ្ញុំមួយទៀតបី នៅជាមួយយាយតែបីនាក់ទេ តូចៗ ។

រឿនៈ ចា៎ ។

រឿនៈ នៅជាមួយយាយ អាពីរនាក់ទៀតទៅកង មួយនៅទំនប់លោក មួយនៅព្រៃលើ ។

រឿនៈ ខ្ញុំហ្នឹងនៅកងប្រឡាយ ។

រឿនៈ ចា៎ ។

រឿនៈ នៅព្រៃលើ នៅកងព្រៃលើ ។

រឿនៈ កាស់ព្រៃ កាប់ឆ្ការ ។

រឿនៈ ៦ អាអូន ហួស វត្តខ្នារទៀត ៦ ។

រឿនៈ ជីកប្រឡាយកាស់ព្រៃកាស់អីអញ្ចឹងទៅ នៅកងអត់មានធ្វើអីទេ គាត់មកកង បែកគ្នា ។

រឿនៈ ខ្ញុំនៅកង អេ អូរចំបក់ ។

រឿនៈ ចេញពីអូរចំបក់មក នៅឡូ អូរចំបក់នៅឡូគ្រឿង ចេញពីឡូគ្រឿងមក ចូលកងនារីប្រមូលផ្តុំមួយថ្ងៃ មួយថ្ងៃនោះ ចេញពីប្រមូលផ្តុំមកគេអោយទៅធ្វើឡូទៀត នៅគេដាក់អោយ ប៉ុន្តែនៅក្មេង គេអោយចូលកងនារី តែនៅក្មេង អោយចូលកងនារីតែម្តងអាហ្នឹង ខ្ញុំវាមេម៉ាយហើយទេ ។

រឿនៈ ១៩៧៦ ។

រឿនៈ អត់ដឹង ទៅកងបាត់ទៅ ។

រឿនៈ ចា៎ ។

រឿនៈ ព្រៃលើហ្នឹង ។

រឿនៈ ឃុំលាយបូរដែរហ្នឹង ព្រៃលើ ត្រាំកក់ដែរហ្នឹង ។

រឿនៈ ចា៎ កាលហ្នឹង ប្អូនជីដូនមួយខ្ញុំ អាម៉ាចហ្នឹង ក៏ស្លាប់នៅហ្នឹងដែរ នៅកងដែរ អាហ្នឹង សុទ្ធតែ និយាយរកជាមួយខ្ញុំអីអញ្ចឹង ដបស្រូវ ហើយតានីមនោះគ្នាអ្នកចាស់ហ្នឹងអោយ បាយ បងហូបអីហ្នឹង មានអ្នកចាស់ ។

រឿនៈ គេយកទៅសម្លាប់ដែរ យកទៅណោះ ទៅកងអីប្រឡាយអី ស្រុកក្រោម០៥,០៩នោះ ។

រឿនៈ ដឹកទូក ។

រឿនៈ ដល់តែហើយ ទូកហ្នឹងវាក្រឡាប់អូន ក្រឡាប់លិចទៅ គេថាវាហ្នឹង ពន្ទិចទូកគេយកវាទៅ សម្លាប់ទៅណាចាស់ទៀត ចាស់ហើយខ្ញុំ ស្លាប់តែជីដូន ជីដូនមួយទេ ហើយមានពោះមួយ អត់មានទេ ពោះមួយនៅតូចៗហើយអត់ហ៊ានមាត់ទេខ្លាច ហើយគ្រួសារហ្នឹងទេ ស្លាប់តែ ប៉ុណ្ណឹ ទេ ។

រឿនៈ អត់ជួប បានតែពីរដង ទេ ។

រឿនៈ ចា៎ ពីរដង ។

រឿនៈ អេ ចូលយូរដែរ បាត់រហូត ។

រឿនៈ ចា៎ គេថាទៅ ដូចថាទៅធ្វើកងរទេះ កងអី ស្រុកលើអញ្ចឹងទៅ ជាងអីអញ្ចឹងទៅ គេ ហៅធ្វើជាងធ្វើអី ។

រឿនៈ អត់ជឿ ដឹងតែថាទៅធ្វើស្ពានហ្នឹង គឺស្លាប់ហើយ ព្រោះថាអោយតែលឺ ថាស្ពាន ស្ពាន ហ្នឹងដឹងតែបាត់រហូត ។

រឿនៈ ពួកខ្មែរក្រហម អ្នកមេ មេកងគេហ្នឹង ។

រឿនៈ ជាងហ្នឹង មានអ្នកក្រៅទេ សុទ្ធតែគ្នាឯង សុទ្ធតែមា ជីដូនមួយមា ជីទួតមួយហ្នឹង ។

រឿនៈ តែគេអ្នកចាស ហើយសួរទៅ ចុះបាត់ពូមុតនៅឯណា គ្រួសារខ្ញុំ អត់ឃើញមក គេយក ទៅធ្វើស្ពាន ។

រឿនៈ អត់ហ៊ានទេ តែសុំគេយកទៅបាត់ទៀតឥលូវហើយ ដឹងថាបាត់អញ្ចឹង គឺបាត់ហើយ ដឹងហើយ ដឹងព្រោះយាយខ្ញុំគាត់ប្រាប់ យាយខ្ញុំថា បើសិនជាលឺ មិនបាច់សុំគេចង់ដឹងអី ទេ នៅអោយស្ងៀមទៅ ។

រឿនៈ យាយខ្ញុំ យាយបង្កើតគាត់ខស្សរ៉ាហ៍ប្រាប់ យាយហើយមីងស្រី ស្រីគាត់ ខស្សរ៉ាហ៍ប្រាប់ បើប្រុសៗវិញ មិនសូវប្រាប់ទេ គេលាក់ការណ៍ ។

រឿនៈ បើស្រីប្រាប់ លួចខ្ចប់អង្ករ ខ្ចប់បាយ ដំឡូងថ្នក់សំពត់ យកមកអោយក្ដួយហូបអោយបងប្អូន អាហ្នឹងមានស្រី បើថា ខាងប្រុស សុទ្ធតែសាច់ថ្ងៃហើយ ។

រឿនៈ ម្ដាយខ្ញុំនៅ ។

រឿនៈ ឪពុកនៅ សព្វថ្ងៃ ហ្នឹង ប៉ុនតែចាស់អស់ហើយ ។

រឿនៈ ៧៧ ៧៨ឆ្នាំអស់ហើយ ។

រឿនៈ ម្ដាយខ្ញុំ ធូ សឿង ។

រឿនៈ ឪពុក គីម ពុំ ។

រឿនៈ ឪពុក ៧៨ ។

រឿនៈ ម្ដាយ ៧៧ ។

រឿនៈ នៅទាំងពីរ ។

រឿនៈ ប៉ុន្តែ ចាស់ ចាស់ហើយណាអូន ចាំ៎ គាត់បងប្អូនគ្នាមួយឆ្នាំ ។

រឿនៈ អត់ទេ អូន អត់ជួបទេ ។

រឿនៈ ចាំ៎ ខ្ញុំរាប់ខែ បាន បានមកផ្ទះម្ដង សុំគេអត់អោយមកទេ នៅកងវហូត ។

រឿនៈ នៅភូមិ ប៉ុន្តែគាត់កងនៅជិតអញ្ចឹងទៅណា ខ្ញុំចេញឆ្ងាយទៅកងអញ្ចឹង ជួនកាលខ្ញុំទៅទំនប់លោក ហើយទៅចំការសៀង ។

រឿនៈ អត់សូវមកទេ អោយតែក្មេង អត់សូវអោយមកទេ បើចាស់គេអោយមកជួប ។

រឿនៈ ហើយខ្ញុំ តាំងពីបែកអញ្ចឹងទៅ គេមានសូវអោយមកអត់ទេ ។

រឿនៈ បីខែ-បួនខែ បានជួប ឪពុកម្ដាយមួយដង កាលរត់ទៅ ខ្ញុំរត់ទៅដល់ ភ្នំលះបង់ ៦ណោះណា ។

រឿនៈ ហើយឪពុកខ្ញុំរត់ទៅវៀតណាមអោះ ម្ដាយខ្ញុំ ។

រឿនៈ ៧៩ ហ្នឹងអាំ៎ បែកហ្នឹង ។

រឿនៈ ហើយឪពុកខ្ញុំ គាត់រត់ទៅដល់វៀតណាមអោះ រត់ទៅដល់ភ្នំ លះបង់៦ណោះហើយឪពុកខ្ញុំ រត់ទៅវៀតណាម ។

រឿនៈ ១៩៧៩ ហ្នឹង ។

រឿនៈ គាត់រត់ទៅវៀតណាម ដល់តែគេទារទៅដល់ ទៅដល់ស្រុកកោះអណ្តែត ទៅដល់ហ្នឹងអញ្ចឹង គេទៅកៀរដល់ហ្នឹង គាត់កំពុងពិល កំពុងយោលអោះ គាត់ទៅ អញ្ចឹងទៅគេកៀរមកវិញៗគាត់ហ្នឹងទៅ ដល់វត្តទេ គាត់ខុង ចាក់ជ្រុំខុង ហើយខ្ញុំរត់ពីលិចមក ។

រឿនៈ រត់ពីលិចមកខ្ញុំ វង្វេងឪពុកម្តាយ ខ្ញុំដើររកជួបបងប្អូនស្រុកភូមិអញ្ចឹង គាត់ថាពុកឯងម្តាយឯង រត់ទៅវៀតណាមហើយទៅ គាត់ចូលអត់ដល់ផង គេស្កាត់បានមកវិញមកវិញហើយ ដល់តែហើយខ្ញុំដើររកគាត់អត់ឃើញទេ រយៈពេលពីរខែអូន ខ្ញុំនៅតែជាមួយតែមាក្មេ សុំទៅនៅគេ សុំនៅ៤-១០ថ្ងៃ, ៤-១០ថ្ងៃអញ្ចឹងដើររកគាត់ ដើរទៅជួបគាត់ បាខុង សួរ ទៅជួបនៅបាខុង គាត់ទៅ ឪពុកគាត់ ដើរជួបគាត់យំ គាត់រែកទឹកនឹងផ្នាំង អត់មានអីប្រើ មួយខាងផ្នាំង មួយខាងកំសៀវរែកទឹក ។

រឿនៈ អាហ្នឹងគេមូល មូលជាមួយគាត់ ។

រឿនៈ ចាំ បែកតែខ្ញុំ ខ្ញុំទៅឆ្ងាយ កូនតូច តូច ហើយទៅកងជិត ជួបគាត់ ។

រឿនៈ ចាក់ជ្រុំ ជុំ កាលសៀង ។

រឿនៈ កូនមួយ ។

រឿនៈ ចាំ ។

រឿនៈ នៅ ការប្រពន្ធអោយហើយ ។

រឿនៈ ប្រុស ទើបតែការអោយខែផល្គុននេះ កូនតែមួយប្រុស ហើយខ្ញុំកាលពី៧៩ហ្នឹងបែកខ្ញុំចូលធ្វើការទីរួមខេត្តហ្នឹង អត់សូវចេះអីហ្នឹងគេទេ ប៉ុនតែចេះតែធ្វើការអញ្ចឹងទៅ ដល់តែហើយ អោយចេញពីទីរួមខេត្តហ្នឹង អោយកាត់ដេរ កាត់ដេរពាណិជ្ជកម្មហ្នឹង កម្មករពាណិជ្ជកម្ម ដេរហ្នឹង នៅហ្នឹងរហូតមកអញ្ចឹង បានខ្ញុំឈប់ ។

រឿនៈ ធ្វើបាន១៨ឆ្នាំ អាអូន ទើបតែឈប់ឆ្នាំ ៩០ ប៉ុន្នាន ។

រឿនៈ ចាំ បោះឆ្នោតពីរដងហើយ បានខ្ញុំឈប់ ឈប់អត់អាណា នៅជាមួយយាយតា ។

រឿនៈ ខ្ញុំ នៅភ្នំលិចអោះ ធ្វើឡ ។

រឿនៈ ចាំ អត់ដឹងផង ។

រឿនៈ ចាំ ឡក្បឿងហ្នឹង នៅជាមួយពួកទ័ព ប៉ុល ពតទៀត ។

រឿនៈ ឃើញកប៉ាល់ហោះ ហោះលើ ហើយពួកគេ គេមានគេអូ តែបែកភ្នំពេញ បែកតាកែវ អញ្ចឹងបែកប៉ុល ពត យួនមក ។

រឿនៈ បែកអញ្ចឹងហើយ បែកយួនមក វៀតណាមទៅដល់ ហើយដល់តែហើយ គេថាបែក គេនាំខ្ញុំហ្នឹងដឹកដំបូង ដឹកពួកខ្ញុំហ្នឹងទៅ ដាក់ភ្នំបូផង់ សេរីសោភ័ណ ខ្ញុំលះបង់ ។

រឿនៈ ដឹកយកទៅហ្នឹង អោយយើងរត់ទៅលើទៀត រត់ហើយខ្ញុំថា រត់ទៅអាម៉េចទេ ខ្ញុំខ្លាចគេថា រត់មកកើត បែបយួនអា ក ។

រឿនៈ គេអត់អោយមកទេណា ។

រឿនៈ ខ្ញុំថា ខ្ញុំមិនដែលឃើញយួន អ្នកអាកទេ មានតែប៉ុល ពត ខ្ញុំនឹកនៅក្នុងចិត្តណាបីនាក់ បីនាក់ បីនាក់បងប្អូនជីដូនមួយ ជីដូនមួយមេឃុំហ្នឹង ហើយនិងមាឌហ្នឹង សុទ្ធតែម៉ែដូចគ្នា បីនាក់ហ្នឹង សុទ្ធតែមេម៉ាយ អាមុំ កូនមួយស្លាប់ដែរ មាឌ អត់កូនទេ ។

រឿនៈ អាហ្នឹងកូនមួយ ដល់តែអញ្ចឹង រត់មកកូនហ្នឹង និយាយទៅ មិនមែនកូនបង្កើតទេ កូនសុំទៀត ។

រឿនៈ ចាំ សុំទេ ទើបតែសុំកាល ធ្វើការតលូវនេះទេ កូនបង្កើតអត់មានទេ អត់មានទេ ។

រឿនៈ ដឹង ប៉ុន្តែម្តាយវាស្លាប់ ។

រឿនៈ ប៉ុន្តែខ្ញុំចេះតែថាកូនខ្ញុំ ចង់ស៊ីប្រាក់ខែរហូតទៅណា ខ្ញុំចូលធ្វើការហ្នឹង កូនបង្កើតអត់មានទេ ហើយខ្ញុំអត់ដែលយកគ្រួសារទៀត អត់រហូតមានតែខ្ញុំអត់យក ខ្ញុំថាខ្លាចគេសម្លឹងតែឃើញយើងមានបន្តិចបន្តួចមានការងាររធ្វើអីអញ្ចឹងទៅណា ។

រឿនៈ សល់ទ្រព្យរបស់បន្តិចបន្តួច អត់យកសុខចិត្តចិញ្ចឹម ប្អូនអោយរៀន ប្អូនខ្ញុំ៥នាក់ រៀនទាំងអស់ បានបាក់ឌុប បានឌីប្លូម ខ្ញុំសព្វថ្ងៃអត់មានការងាររធ្វើ ហើយសព្វថ្ងៃបាន ប្អូនប្អូន ជួយចិញ្ចឹមដែរ គេអោយខ្ញុំឈប់ វាជួយចិញ្ចឹម ។

រឿនៈ ចិញ្ចឹមការកូន គេអោយលុយមកការតើ អត់មានលុយឯណា គេអោយលុយមក មួយលាន ការកូនហ្នឹង ។

រឿនៈ ការមួយលាន អោយលុយថ្លៃផ្ទះគេ ហើយហៅបងប្អូនស្គាល់ខ្ញុំធ្វើការហ្នឹង គាត់អ្នកជំពាក់ចំណងដៃបានប៉ុន្មានជិត៣លាន អត់ជំពាក់គេទេរួចរាល់សល់ បានម្ភៃម៉ឺន ទិញជ្រូកអោយចិញ្ចឹមបានរាល់ថ្ងៃ ។

វឿនៈ  ចា៎ ចែកអោយគេមួយ ទុកមួយ សល់ប៉ុន្មាន គ្រាន់តែទិញម្ហូបទិញអី ។

វឿនៈ  សួរ រកអត់ឃើញទេ ។

វឿនៈ  ចា៎ អត់ទេ ឃើញតែឆ្អឹង ឆ្អឹងមិនដឹងអាណា ជាអាណាទេ គាត់ស្អីបូ មិនដឹងពីវត្ត ស្រុកបុស្សឺហ្នឹងមិនដឹង ហើយវត្តមួយទៀតស្អី គេហៅសម្លាប់ច្រើននោះស្អី ។

វឿនៈ  ក្រាំងតាចាន់ហ្នឹង ខ្ញុំទៅឃើញឆ្អឹង ខ្ញុំទៅប័ង្សសកូលពូខ្ញុំឥវ៉ាន់ធ្វើគ្រូហ្នឹង គេចារឈ្មោះអា៎ គ្រូ សូរជាល់ហ្នឹង សូររាជហ្នឹង ។

វឿនៈ  គេចារឈ្មោះនៅហ្នឹងតើ ។

វឿនៈ  សព ស្លាប់នៅហ្នឹង បានកូន កូន ទៅបង្សុសកូល ទៅ ។

វឿនៈ  ហើយឆ្អឹងច្រើន ។

វឿនៈ  អើ ៤នាក់អូន ។

វឿនៈ  នៅពីរ ។

វឿនៈ  ពីរ ប៉ុន្តែនៅបាត់ដំបង ។

វឿនៈ  ចា៎ អញ្ចឹង ហើយស្រុកកំណើត ម្តាយក្មេកខ្ញុំនៅតានី ។

វឿនៈ  នេះ កន្លែងអន្តរជ័យហ្នឹង ។

វឿនៈ  ឈ្មោះយាយវ៉ាល ។់

វឿនៈ  ហើយឪពុកក្មេកខ្ញុំហ្នឹងនៅព្រៃផ្អាវនេះ ។

វឿនៈ  ខ្ញុំស្គាល់ខ្លាំងនេះជាងគេតាម៉ុកហ្នឹងតែម្តង ។

វឿនៈ  ហើយមួយទៀត តាបូ បងប្អូនតាម៉ុកហ្នឹង ហើយចុះគាត់កាន់កាប់ឡូ តា បងប្អូន តាម៉ុក ។

វឿនៈ  ចា៎ តាបូ ។

វឿនៈ  ប្អូនបង្កើតអា៎ ហើយតាសានមួយទៀត បងថ្លៃ ប្អូនថ្លៃគេ ។

វឿនៈ  ដំបូងនៅឡូអូចំបក់នេះ ។

វឿនៈ  ឡូក្បឿង ដុតក្បឿងដុតឥដ្ឋហ្នឹង ហើយដល់តែចេញពីហ្នឹង គេយកខ្ញុំអ្នកចេះៗទៅឡូ នៅចំការទៀងហ្នឹង ទៅបង្រៀនពួកទ័ព បង្រៀន ពួកនេះទៀត ។

រឿនៈ ហើយខ្ញុំ១៧ ខ្ញុំប្រាប់ថា១៧ ទៅនៅចំការអញ្ចឹង អត់ជឿទៀត ហើយខ្ញុំត្រង់ទៀតខ្ញុំថា ខ្ញុំ១៧ ដល់តែហើយ អាពួកក្មេងៗៗគេស្រឡាញ់ពួកខ្ញុំ១៧នោះ ។

រឿនៈ ពួកទ័ពនោះ ខ្ញុំថាអត់ទេ ខ្ញុំមេមាយ ប្រពន្ធទាហានហើយ គេថាកុំនិយាយអញ្ចឹងប្រយ័ត្នងាប់ គេប្រាប់ខ្ញុំចេះនិយាយលែង តែខ្ញុំអត់ស្រឡាញ់វាពីរបីនាក់ហ្នឹង ដល់តែហើយទៅប្រាប់វាត្រង់អញ្ចឹង វាថាអី បងរឿន ឯងនិយាយអញ្ចឹងប្រយ័ត្នងាប់ ដល់តែហើយខ្ញុំលែងហ៊ាននិយាយទៅ ខ្ញុំបីនាក់ មេម៉ាយទាំងអស់ ។

រឿនៈ ផ្ទះតាម៉ុក អត់ដែលទៅធ្វើទេ គ្រាន់តែទៅលេង ។

រឿនៈ កាលពីជំនាន់ប៉ុលពត ។

រឿនៈ ទៅលេង គេអោយទៅបើកស្បែកជើង គេហៅទៅ គេហៅសុទ្ធតែក្រមុំ ក្រមុំ ។

រឿនៈ ឡអូរចំបក់ហ្នឹង គេអោយទៅ ក្រមុំ ក្រមុំ អត់ស្បែកជើងកង់ឡាន ។

រឿនៈ គេអោយអើ ពួកឡហ្នឹងទៅ ។

រឿនៈ គេមានហៅខ្ញុំមេម៉ាយឯណាគេហៅសុទ្ធតែក្រមុំហ្នឹង ហើយចុះសុទ្ធតែនៅក្មេងៗ ។

រឿនៈ គេអត់ដឹងផង ។

រឿនៈ ហើយកាលហ្នឹងនៅក្មេងវាស្អាត ។

រឿនៈ នៅ គេហៅសុទ្ធតែក្រមុំ ។

រឿនៈ ហើយនៅជាមួយទ័ព គេ គេអោយហូបឆ្អែតដែរ កាលហ្នឹង ។

រឿនៈ ៧៧ ។

រឿនៈ ចា៎ ត្រឹម៧៧ ។

រឿនៈ ១៩៧៨ហ្នឹង ខ្វះហើយ ។

រឿនៈ ១៩៧៧ ។

រឿនៈ បានមួយឆ្នាំដែរ ១៩៧៧ ហ្នឹង ។

រឿនៈ នៅអូរចំបក់នេះ ។

រឿនៈ ចា៎ ទៅនោះអត់ទេ ។

រឿនៈ អាហ្នឹងគេហៅឡចំការសៀងគេនោះ ។

រឿនៈ ហ្នឹងហើយ ចំការសៀង ។

រឿនៈ  ហ្នឹងហើយ ចំការសៀង ភ្នំដីរ រមៀលហ្នឹង ។

រឿនៈ  អត់ទេ ក្នាគេ គេហូបរបស់គេទៅ ជាមួយពួកតាបូ តាអីហ្នឹង ទៅ។

រឿនៈ  ហើយខ្ញុំ នៅកងនារី ស្រី ស្រី គេមាន ១៧ នៅច្រើន។

រឿនៈ  ស្រី ស្រី ឈ្មោះ អ៊ី សៀន។

រឿនៈ  អត់ដឹងទេ។

រឿនៈ  សៀនម្នាក់ហើយនិង ពូណែមម្នាក់ ណែម សុទ្ធតែអ្នកចាស់ សៀន ហ្នឹងនៅស្រែរនោង ជួបរាល់ថ្ងៃ។

រឿនៈ  ស្រែរនោង ហើយពូណែមហ្នឹងនៅអានេះ ស្រែជំរៅជួបទៅវត្ត ទៅអីជួបគ្នាហ្នឹង។

រឿនៈ  ចាំ៎ គាត់បេះតែស្គួរ ធម្មតាអញ្ចឹង។

រឿនៈ  អី ចាំតែចិត្តល្អអោយទៅ ចិត្តល្អឥលូវហើយ ។

រឿនៈ  សៀន។ ។

រឿនៈ  ចាំ៎ ។

រឿនៈ  ស្រែរនោង ។

រឿនៈ  អូ មិត្តរ៉េមមួយទៀត។

រឿនៈ  រ៉េម មួយទៀត ប្ដីធ្វើទ័ពអាំ៎ រ៉េមមួយទៀត។

រឿនៈ  ក្ដោបក្ដាប់ហ្នឹងវាមានបីនាក់។

រឿនៈ  មេប្រធានគេយឿន។

រឿនៈ  ចាំ៎។

រឿនៈ  អី លិចនេះ នៅជិតនេះដែរហ្នឹង។

រឿនៈ  ស្រី។

រឿនៈ  ស្រីគាត់ចាស់ គាត់អត់មានប្ដីទេណា នៅផ្លូវអន្លក់តានូ ។

រឿនៈ  នេះកន្លែងព្រៃជិតលែងអន្គុញ លេងអី ខែចូលឆ្នាំនេះ។

រឿនៈ  ឃុំលាយបូរ។

រឿនៈ  ចាំ៎ រ៉េម ហើយសៀន មួយ។

រឿនៈ  ចាំ៎ ហើយភូមិស្រែជំរៅនេះមួយ ណែម។

រឿនៈ  សុទ្ធតែប្រធានកងគេអាណា ។

រឿនៈ  ស្គាល់  នៅជួបគ្នា  ជួប  សួរធម្មតា ។

រឿនៈ  ដូចបងប្អូនអញ្ចឹង ។

រឿនៈ  ហើយចុះធ្វើអាម៉េច  បើមកតលូវ  គេឃើញតែធម៌ព្រះ  យើងស្តាប់លោកទេសយើងដឹង
ហើយ ។

រឿនៈ  នរណាសាងអីឃើញហ្នឹងហើយ ។

រឿនៈ  ទៅគ្នាច្រើនអូន ។

រឿនៈ  ទៅគេអោយខោអាវ  អោយអាស្បែកជើងកង់ឡាន  ហើយក្រមាក្រហម  ហើយ
សំពត់ខ្មៅ  អាវខ្មៅ  មួយកំផ្លេ  មួយកំផ្លេរបស់គេ ។

រឿនៈ  អរម៉ាំ ។

រឿនៈ  អត់ទេ  បានតែមួយដងហ្នឹង ។

រឿនៈ  អត់មានកម្មវិធីអី  គេអោយថា  ឃើញមកឃើញថាអត់ស្បែកជើងចូលឡូហ្នឹងវាក្តៅ ។

រឿនៈ  ហើយចុះចូល  អាពេលខ្វា  ដេះ  ខ្វាអស់ហ្នឹង  យើងដុតឡូហ្នឹង  វាក្តៅ ។

រឿនៈ  អត់ទេ  គេហៅឈ្មោះអោយយក  ទៅ  ។

រឿនៈ  កូនចៅតាម៉ុកហ្នឹង  មិនមែនតាម៉ុក  ជាអ្នកចែកទេ ។

រឿនៈ  ប៉ុនតែ  ផ្ទះគេនៅហ្នឹង ។

រឿនៈ  កណ្តាលទឹកហ្នឹង  មិនដែលបានទៅហ្នឹង  ស្រាប់តែទៅ  យើងនៅខាងក្រោផ្ទះខាងគេ ។

រឿនៈ  មិនទាន់ហើយទេ  ។

រឿនៈ  ខ្ញុំ ។

រឿនៈ  មានបានអី  បានតែស្បែក  ខោអាវ  មួយកំផ្លេ  ហ្នឹង ។

រឿនៈ  នៅទេ  នៅទេ  ទាល់តែស្ពានធ្វើហើយ  ពីកើតមក  ស្ពានចូលហ្នឹង ។

គៀនៈ  មីងមានដឹងថាគេសង់ផ្ទះទេ?

រឿនៈ  អត់ដឹង  អត់ដឹងថាធ្វើអី  លឺតែថាធ្វើផ្ទះតាម៉ុក  ធ្វើផ្ទះតាម៉ុក ។

រឿនៈ  ស្រាប់តែទៅកំពង់អំពិល  មានមួយទៀត  ឃើញផ្ទះតាម៉ុកទៀតនៅលើទឹកហ្នឹងតែម្តង ។

រឿនៈ  កំពង់អំពិល ។

រឿនៈ  កំពង់អំពិល ផ្លូវទៅស្រុកឃ្មួនហ្នឹង ផ្លូវទៅកំពង់ក្រសាំងហ្នឹង ។

រឿនៈ  ទៅអញ្ចឹង ទៅអាកន្លែង ត្រឡូងទានហ្នឹង ទៅខ្នុតទឹកហ្នឹង ។

រឿនៈ  ខ្ញុំទៅដល់ ។

រឿនៈ  ផ្ទះតាម៉ុក ធ្វើបីជាន់ ធ្វើលើទឹកតែម្តង សុទ្ធតែលើទឹក នៅក្នុងទន្លេតែម្តងអូន គេចាក់ផ្ទះគេខ្ពស់ ទៅដល់ទៅធ្វើទំនប់នៅហ្នឹងដែរណា ទំនប់ហ្នឹង ខ្ញុំស្គាល់តែតាម៉ុក ស្គាល់តែពីរហ្នឹងទេ ។

រឿនៈ  តាមផ្លូវ កំពង់អំពិល ខ្ញុំតាមផ្លូវ យើងទៅពីនេះ ខ្ញុំទៅតាកែវទៅវត្តភ្នំខ្វែងណា ។

រឿនៈ  ដល់តែអញ្ចឹងទៅកើតអញ្ចឹង ទៅតាំងពីល្វាហ្នឹង ទៅថ្នស ថ្នស បកមកត្បូងអញ្ចេះ ទៅកើតទៅ ទៅត្បូងអំពិល ។

រឿនៈ  ហ្នឹងស្រុក បូរី ជលសារ អាំ ប៉ុន្តែផ្ទះតាម៉ុកនៅលើទឹក ។

រឿនៈ  ហ្នឹងហើយ លើទឹក ។

រឿនៈ  តូចជាងទេ ។

រឿនៈ  ផ្ទះបីខ្នង ផ្ទះក្បឿង ។

រឿនៈ  ឈើ ប៉ុន្តែក្រោមហ្នឹងគេចាក់សរសរ ទើបតែចាក់សរសរធំៗ មិនមែន សរសរដូចផ្ទះយើងទេណា ។

រឿនៈ  ខ្លាចទឹកវាយបាក់ សរសរធំៗ ធ្វើដូចស្ពានអញ្ចឹង ហើយចុះទំនប់ប្រឡាយ រហូតទំនប់ប្រឡាយយើងនោះ ជីកនោះទំនប់ប្រឡាយ ហើយខាងដល់មកនេះ ផ្លូវទៅកោះអណ្តែត ផ្លូវទៅកោះអណ្តែតហ្នឹងកន្លែងហ្នឹងគេមានឡគេមួយ ឡហ្នឹង ឡគេដុត ខ្មោចទេណា ដល់តែគេធ្វើមនុស្សរុញចូលហ្នឹង អ្នកជាប់គុកទេណា អ្នកជាប់គុកទេណា អ្នកទោស ឡហ្នឹងអ្នកយើងឃើល្មមៗៗអី គេរុញចូលហ្នឹង ឆាប់ហ្នឹងហើយ ឡខ្មោច គេធ្វើដី ។

រឿនៈ  អត់ទេ អត់មានទេ ។

រឿនៈ  មួយភ្លែតមកវិញ ។

រឿនៈ  បានតែស្បែកជើង ខោអាវមួយកំភ្លេ ។

រឿនៈ  ឡានគេ ។

រឿនៈ  ចាំ ឡានគេ ហើយអ្នកនៅឡហ្នឹង ប្រហែល២០នាក់ហ្នឹង ។

រឿនៈ  អាឡានគេអត់ដឹបូលនោះ ។

រឿនៈ  ឡូ ។

រឿនៈ  តាសៀង ។

រឿនៈ  តាបូ  ប្រធានកង  ហ្នឹង ។

រឿនៈ  ជួប  គាត់ប្រធានកង  ក្ដោបក្ដាប់នៅហ្នឹង  តាបូ ។

រឿនៈ  អឺ  គេនៅហ្នឹងគេចេះតែល្អជាមួយយើងហើយ  ប៉ុន្តែចិត្តគេមិនដឹងជាយ៉ាងម៉េច ។

រឿនៈ  ល្អ  តែចិត្តគេនៅតែកាច  អត់ហ៊ាននិយាយអីផង  គេប្រជុំស្ងាត់ៗ  គេដាក់ខ្ទាំងដែរហ្នឹង គេប្រជុំ  ប្រជុំមិនអោយយើង  យុវជន  នារីហ្នឹង  គេមិនអោយអង្គុយជិតគ្នា  មិនអោយជួបគ្នា  និយាយគ្នា  មានទោស ។

ជាតិៈ  បាទ ។

រឿនៈ  មុជទឹកគេអោយទៅថា  ត្រើយម្ខាង  ទំនប់ហ្នឹង  មានទំនប់  មានប្រឡាយ  ដល់តែហើយ អោយយុវជនហ្នឹង  នៅមុជផ្សេងទៅអញ្ចោះទៅ  ភ្នំវាមានដាច់អញ្ចោះ  ភ្នំបែកចាន  ហ្នឹង ។

រឿនៈ  អញ្ចោះ  ហើយមានស្ទឹងហ្នឹង  ខាងស្រីមកមុជអញ្ចោះ  អត់អោយជិតគ្នាទេ  ជិត  គ្នាអត់បានទេ  ហូបបាយ  ក៏អត់មានហូបជិតគ្នាដែរ  គេដាក់ចង្រ្កានដោយខ្លួនទេ  ។

រឿនៈ  ខាងស្រីៗផ្សេងអញ្ចឹងទៅ  រោងសំរាន្តក៏អញ្ចឹងដែរ  រោងគេធ្វើវែងអញ្ចឹងទៅណា  អោយរោងស្រីៗសំរាន្តដោយខ្លួនផ្សេង  យាមស្រីៗហ្នឹង  យាមផ្សេងទៅ ។

រឿនៈ  ប្រុសៗគេសំរាន្តផ្សេងទៅ  យប់ឡើង  ស្មា  ឆ្កែចចក  ខ្លា  ទោច  យំពេញព្រៃ  អស់ហើយ ហើយអត់ហ៊ានមាត់ទេ  ហើយគេអោយខ្ញុំយាមផាវ៉ាន់  ខ្ញុំយាមនៅរោងហ្នឹង  អត់ហ៊ានចុះទេ

រឿនៈ  ហូបចុកខ្វះ  ហូបដំឡូងមី  បាយបន្តិច  បន្តិចអញ្ចឹងទៅ ។

រឿនៈ  ធ្វើតែឡក្បឿងហ្នឹង ។

រឿនៈ  កាយដីឥដ្ឋ  ជាន់ដីឥដ្ឋហ្នឹង ។

រឿនៈ  វែក  វែកពី  នោះ  ពីខាងដើមត្នោតនោះ  អូន  វែកមកចាក់អញ្ចឹងទៅ  ដាក់លាយ ។

រឿនៈ  ក្បឿង  ធ្វើស្រកាលេញ  ច្រើន  ច្រើនតែស្រកាលេញ ។

រឿនៈ  អាក្បឿងក្បាច់ហ្នឹងមិនសូវមានទេ  ក្បឿងក្បាច់ធ្វើនៅឡអូចំបក់នេះ  អាហ្នឹងគេវាយពុម្ព ។

រឿនៈ  កាច់  កៀរ  ដាក់ហាលទៅ ។

រឿនៈ ចា៎ ។

រឿនៈ ស្រកាលេញ ។

រឿនៈ គេរៀបឥដ្ឋ គេវាយឥដ្ឋគាន់ៗដាក់ផេះ ហើយខ្ញុំចូលផេះ ភ្នែកហ្នឹងដុះកន្ទុយថ្ងៃន ។

រឿនៈ មិនដឹងដឹក ទៅឯណា ។

រឿនៈ ចេញច្រើន ថា ដឹកអោយមិត្តយើង មិនដឹងយកទៅឯណា មិត្តយើងហ្នឹង ។

រឿនៈ ចា៎ លឺតែមិត្តហ្នឹង មិនដឹងជាមិត្តនៅឯណា ហើយចុះអាមិត្តយើង មិនដឹងយកទៅឯណា ឃើញតែគេដឹកចេញ ។

រឿនៈ លឺតែ មេឃុំ មេឃុំ តានៅ តាហូញ អញ្ចឹងទៅ ។

រឿនៈ អឺ មិនឃើញ តានៅហ្នឹង ស ។

រឿនៈ តាហូញ ហ្នឹង ខ្មៅ ។

រឿនៈ ប៉ុល ពតលឺតែឈ្មោះ ប៉ុល ពតៗ ។

រឿនៈ ចេះតែលឺតាមគេនិយាយអញ្ចឹងទៅ ។

រឿនៈ លឺ ប៉ុល ពតៗហ្នឹង ប៉ុន្តែអត់ដែលឃើញប៉ុល ពតអាណា ឃើញតែតាម៉ុក ហ្នឹង តានៅ តាហូញហ្នឹង ហើយអ្នកចាស់ៗហ្នឹង ក្នាគេហ្នឹងសុទ្ធតែប៉ុល ពតហ្នឹង ប៉ុន្តែខ្ញុំអត់ហ៊ាន មាត់ទេ ណា ចេះតែប៉ុល ពតៗមិនដឹងជាប៉ុល ពតនៅឯណា ។

រឿនៈ តែក្នាឯងហ្នឹង សុទ្ធតែអ្នកចាស់ៗហ្នឹង ។

រឿនៈ អត់ លឺតែឈ្មោះតាម៉ុកហ្នឹង ។

រឿនៈ អូ ខៀវសំផន ថាស្លាប់ហើយហ្នឹង ។

រឿនៈ ចា៎ ។

រឿនៈ ខៀវ សំផន អឺ គៀត ពិន គេថាស្លាប់ ហើយ ។

រឿនៈ ចេះតែលឺគេថាហ្នឹង ហើយនៅវត្តអំពិល ដល់តែពេលបែកមក ស្រាប់តែឃើញ កូន ។

រឿនៈ ហើយចុះ សម សារី ហ្នឹង ស្រាប់តែឃើញកូនហ្នឹង សម រង្ស៊ី ហ្នឹង អឺ នៅមានតពូជ ទៀតម

រឿនៈ ស្មានតែស្លាប់អស់ហើយម

រឿនៈ លឺតាម៉ុក, តាបូ ។

រឿនៈ ចា៎ ខ្ញុំស្គាល់ដាក់ តែគាម៉ុកហ្នឹងតើ គាបូ, គានៅ ,គាហូញ ។

រឿនៈ អើ ស្រាប់តែឥលូវ គេថានៅហ្នឹង កាលពីមុនគេថាស្លាប់ហើយ តែឥលូវថានៅហើយ មិនដឹងនៅប្រទេសណាឥលូវ ។

រឿនៈ មកវិញហើយ?

រឿនៈ មិនដឹងចំណាស់ប៉ុន្មានហើយទៅ?

រឿនៈ គាហ្នឹង ដូច ស្រករ សម្តេច ។

រឿនៈ បន្តិចបន្តួចទេ ។

រឿនៈ ចូល បើ ប្អូន ខ្ទង់មួយឆ្នាំ ពីរ ឆ្នាំទេណា ហើយចុះបងប្អូនសម្តេចដែរ?

រឿនៈ ខ្ញុំឃើញកាលពីនៅក្មេង ក្មេង តែឥលូវ ឃើញក៏អត់ស្គាល់ដែរ ។

រឿនៈ ឃើញរូបថត ។

រឿនៈ ខៀវ សំផន ចា៎ រូបថត បើឪពុកម្តាយខ្ញុំ គាត់ស្គាល់ទាំងអស់ ហ្នឹង ដាក់តែសម្តេច ស្គាល់ ។

រឿនៈ ខ្ញុំ កាលពីជំនាន់ប៉ុល ពត ខ្មែរក្រហមហ្នឹង ខ្ញុំគិតថា មិនថារស់ទេ មិនថា រស់ដល់សព្វថ្ងៃទេខ្ញុំ ។

រឿនៈ ខ្ញុំថា អត់ត្រឡប់ក្រោយវិញទេ ព្រោះវាចេះ ចេះតែសម្លាប់អញ្ចឹង ខ្មែរ ។

រឿនៈ ចា៎ ព្រៃផ្សៃ ខ្ញុំថា អត់មានមកក្រោយវិញទេ សម្លាប់ចេះអស់ហើយ វាអ្នកចេះ អោយតែលឺចេះ យកសម្លាប់ ចេះយកសម្លាប់ ។

រឿនៈ អត់រីកចំរើនទេ ព្រោះអស់មនុស្សចាស់ហើយ ។

រឿនៈ សម្លាប់ឃើញតែអញ្ចឹង ថាគេសម្លាប់ហ្នឹង គេ យក ទឹកដី ទៅជាអាម៉េច នឹកឃើញ វា នៅក្មេងដែរ មិនសូវដឹង ។

រឿនៈ មិនដឹងជាយកទឹកដីយ៉ាងម៉េច ថាអ្នកចេះ នឹកឃើញអ្នកចេះ គេយកទៅសម្លាប់អស់ យកអ្នកល្ងង់មក អ្នកល្ងង់មក សុទ្ធតែកាប់សម្លាប់ ហើយយកមក សុទ្ធតែស្រុកឃុំ ហើយ អត់ចេះអក្សរទេហើយខ្មៅៗ ។

រឿនៈ ដូចប្រធានកង ប្រធានភូមិ សុទ្ធតែអ្នកល្ងង់ ។

រឿនៈ នៅក្នុងចិត្តខ្ញុំទេណា គេយកអ្នកល្ងង់មកអញ្ចឹង គេសម្លាប់អ្នកចេះអស មិនដឹងជាយ៉ាងម៉េចទេ ចេះតែនឹកឃើញថា បែបអស់ហើយអ្នកចេះ ហើយអ្នកនៅមួយៗហ្នឹង សុទ្ធតែគាត់កុហកទេណា ។

រឿនៈ គាត់កុហកទេ បាននៅសល់ខ្លះហ្នឹង គាត់ត្រង់ស្រាប់អស់ ហើយចុះប៉ូលីសគាត់យកសម្លាប់គ្រូក៏សម្លាប់ ទាហានក៏សម្លាប់ អោយតែចេះបន្តិចបន្តួច អោយតែធ្វើការរដ្ឋអំណាចអី អោយតែលីធ្វើការ សម្លាប់ទាំងអស់ នៅប្រជាជនសុទ្ធសាធ ទុកសុទ្ធតែអ្នកល្ងង់ទុកទាំងអស់ នៅរស់មួយ មួយ សុទ្ធតែអ្នកល្ងង់ ។

រឿនៈ ធ្វើឆ្អតៗ ច្រើនឆ្អតច្រើននៅ ហើយខ្ញុំដល់ពេលកាលនៅ ជំនាន់ប៉ុល ពត ខ្ញុំធ្វើ ដូចពេលនេះ ខ្ញុំធ្វើមិនសូវ មិនសូវដែរ។

រឿនៈ ធ្វើអោយតែរស់ ធ្វើអញ្ចឹងទៅ អោយតែរស់ ធ្វើដូចឆ្អតអញ្ចឹងទៅ ជាអញ្ចឹងទៅត្រូវសើចៗទៅ ត្រូវសប្បាយ ត្រូវគេហៅ ធ្វើមិនដឹង មិនដឹង មុខស្លូតអញ្ចឹង ត្រូវយំៗទៅណា អោយតែរស់ នៅទៅភ្លំលិច ។

រឿនៈ មិនមែនតាម៉ុកទេ ។

រឿនៈ អី ចេះតែខឹង ចេះតែនឹកឃើញរដ្ឋអំណាចៗចេះតែខឹងទៅចេះ ។

រឿនៈ ចង់អោយគាត់ទោស អោយដឹងព្រោះអី តាម៉ុក ហ្នឹង ព្រៃវែងដែរ ។

រឿនៈ ហើយចុះព្រៃវែងទំរាំចូល គេហៅចូលយូរហើយ ទំរាំតែចូល ទាល់តែចាប់បាន ។

រឿនៈ វាអោយធូរ កំហឹងឈឺចាប់ ចេះតែប្តី បងប្អូនអី ស្លាប់ដោយសារអញ្ចឹងអាំ អោយ គាត់ទោសទៅ កុំអោយតាម៉ុកហ្នឹង គាត់នៅស្រណុកពេក ។

រឿនៈ កុំអោយវានៅកាប់សម្លាប់អញ្ចឹង ដឹកនាំ គាត់ហ្នឹងអោយនៅផ្លូវល្អវិញ ។

រឿនៈ អោយគាត់ទោស គាត់ទោសអញ្ចឹងទៅ ដើម្បីអោយកំហឹងឈឺចាប់វាបានរំសាយ អោយធូរចិត្ត កុំអោយចងកំហឹងពីមុន ពីមុនមក ។

រឿនៈ មិនអោយសម្លាប់វិញទេ ព្រោះអី អាពេលស្លាប់ វាហួសហើយ អោយនៅ គ្រាន់ តែកែលំអគាត់ ។

រឿនៈ អោយគាត់ហ្នឹង មកល្អវិញមក ។

រឿនៈ ព្រោះអាមុន វាទៅហើយណា អោយអាអ្នកនៅ រស់វិញ មក មកស្រុកមកភូមិ ។

រឿនៈ សាងគាត់អោយល្អវិញមក ដូចចោរអញ្ជឹងអាំ ណែនាំ អោយបានល្អវិញមក ទាល់តែ អ្នកស្លាប់ ស្លាប់ទៅហើយ ។

រឿនៈ អោយនៅ កសាងអោយ ល្អអីអញ្ជឹង ។

រឿនៈ ជួបគាត់ ខ្ញុំធ្វើល្អវិញជាមួយគាត់វិញទៅ ។

រឿនៈ អត់ទេ ឥលូវហ្នឹង ដូចថា អធន ខន្តី អីអញ្ជឹងអាណា អោយមកល្អ វិញទាំងអស់គ្នាមក ។

រឿនៈ ឥលូវស្តាប់តែលោកទោស លោកអីទៅ ធ្វើបុណ្យធ្វើទានទៅ បើអ្នកស្លាប់ហួសពីមុន ។

ហ្នឹង គ្នា ដូចថា គ្នាដាក់មកបន្ត តាមថ្នាក់អញ្ជឹងទៅណា គេរឹប យើងតឹង ទៅដល់ឥលូវ ។

រឿនៈ ឥលូវវារំសាយចិត្តហើយ ធ្វើម៉េចតាមដលទេ

រឿនៈ ស្គាល់ក៏ខ្ញុំអត់ធ្វើអីគេដែរ វាឥលូវវារំសាយអស់ហើ

រឿនៈ ចាំ លត់ដំទៅ ចប់ត្រឹមហ្នឹងទេ

រឿនៈ អោយចប់ត្រឹមហ្នឹង កែខ្លួន កែអីទៅ ធ្វើម៉េចពីមុនសង្គមវាមានអន្ទាក់ ។

រឿនៈ ឥលូវវារដ្ឋអំណាចយើងវាអត់ដូចមុនទេ ដឹកនាំអោយមកល្អវិញអស់ហើយ ។

រឿនៈ ឥលូវវាធូរ ហើយ លែង ដូចមុនហើយ តាំងពីលេបថ្នាំ លេបអីហ្នឹងទៅ ធូរ ធូរក្បាល កាលពីមុន គិតអូ គិត ឥលូវ ។

រឿនៈ ចង់ដែរហ្នឹងអាំ ប៉ុន្តែវាមិនដឹងធ្វើម៉េចស្រីហ្នឹង ។

រឿនៈ ឈប់ ។

រឿនៈ អឺ ដូចចិត្តលែងនឹកឃើញខឹង អឺ អញ្ជឹងហើយ តមុខទៀតទៅ ក៏យើងកាន់ទៅ យើង ទៅមុខ ធ្វើបុណ្យទៅ ក្រែងលំ ជាតិក្រោយទៅ យើងបានល្អ ។

រឿនៈ ចាំ អោយចប់ត្រឹមហ្នឹងទៅ បើឥលូវវាអញ្ជឹងទៅ ហើយ ចប់ត្រឹមហ្នឹងទៅ យើងកសាង ទៅឥលូវ អ្នកណាកសាងល្អ ឃើញល្អ អ្នកណាកសាងអំពើអាក្រក់ឃើញអាក្រក់ ឃើញឆាប់អូន ទេវតាឥលូវ ពីមុនដល់ដី ពីមុនជាតិក្រោយ ឆ្នាំក្រោយ ឥលូវឃើញ ភ្លាមៗ ។

រឿនៈ ទាន់ហន់ ហើយចុះមើលចោបូន់ថ្ងៃមុននេះ បូន់នៅភូមិអីនេះ ក្បាលក់គោបានមួយ ផ្សាយ វិទ្យុ លុយអស់រលីង លុយ២០ម៉ឺន តែចាប់ដី ប្រពន្ធចង នៅសល់លុយ២០ម៉ឺន ចាយ អស់៧ម៉ឺនទៀត នៅសល់តែ១៣ម៉ឺនទេ ១៣ម៉ឺនទុកពីរកន្លែង ហើយគេចងប្តីប្រពន្ធ

ដល់តែចង់អញ្ចឹង គាត់ថាលុយខ្ញុំនៅក្រោម១០ម៉ឺន នៅលើ៣ម៉ឺន ហើយគេស្រាយប្ដី ចង់មុខ ស្រាយប្ដីអោយយកអោយ មុនដំបូងយកក្រោម ១០ម៉ឺន យកអោយទៅ គេសួរថា បីម៉ឺនទៀត បីម៉ឺន ឡើងយកលើផ្ទះ សួរថាអស់ឥលូវ ថាអស់ហើយ ខ្ញុំទិញគោអស់ ហើយដល់តែថា ទិញគោអស់ គេមើលគោ ដល់តែមើលគោ ឃើញទិញ អស់មែន នៅសល់លុយ១៣ម៉ឺន គេយកអស់ទៅ ១៣ ម៉ឺនហ្នឹង ស្រាប់តែប្រពន្ធ វាអត់ ស្រាយទេណា ចេញផុតចំនួនជា ចំនួនបាន ប្រហែលជាកន្លះគីឡូ គាត់មានទូរស័ព្ទ គាត់គេហៅប៉ូលីស ប៉ូលីសមកចូលចំ ចូលចំប៉ូលីសហ្នឹង ក៏សួរមើល សួរមើលក៏ថា គេឃើង គ្នាគេហើយអាចោរក៏ថា ពួកយើង ហើយដល់តែថាប៉ូលីសថាប្រមូលអស់ឥលូវ ថាប្រមូលអស់ហើយ ហើយដល់តែអញ្ចឹង ប៉ូលីសថាអោយទៅក្រោយ ទៅក្រោយ ទៅក្រាបនៅប្រឡាយ ហើយចោរវាដផ្ទៃគ្នាទៅ បាញ់បាញ់សាប់ពីរ សាប់ពីរមួយបាក់ដៃ វត់រួចៗ

រឿនៈ សាប់ពីរ អាមួយសាប់ផ្កាប់មុខ អាមួយសាប់ផ្ងារ ហើយសាប់ទៅ ស្រាប់តែស្រុកភូមិនៅ ហ្នឹងៗ

រឿនៈ ដូច អាក្រកៗ់

រឿនៈ ទេ ឥលូវគាត់សាងតែធ្វើបុណ្យធ្វើទានអីទៅ អេ មានអីមិនមាន គាត់សាង ហើយឥលូវ គាត់សុំសីលអស់ហើយ ៗ

រឿនៈ គាត់ធ្វើទៅវាចេះតែរំសាយ រំសាយកាត់បន្តិចៗអញ្ចឹងទៅណាអូន គាត់ធ្វើទៅបានល្អ របស់គាត់ដែរអាំ រំសាយ រំសាយអស់ គាត់ឥលូវចាស់ គាត់មកសុំសីល ហើយ គាត់ធ្វើ បុណ្យធ្វើទានគាត់អស់ហើយ ៗ

រឿនៈ យុត្តិធម៌ ៗ

រឿនៈ ធ្លាប់លឺយុត្តិធម៌ វាអធន ខន្តីហ្នឹង ៗ

រឿនៈ ចាំ ៗ

រឿនៈ នៅក្នុងចិត្តខ្ញុំ ធ្វើតែយុត្តិធម៌ នៅក្នុងចិត្តថា អធនហ្នឹង អត់មានខឹងទេ ខន្តីហ្នឹង អត់ខឹងទេ ទៅមើលរឿងអញ្ចឹង អត់មានខឹងអីទេ លែងខឹងលែងអីហើយ ឈប់ ៗ

រឿនៈ រាប់អានធម្មតា លែង ខឹង លែងអីអស់ហើយ ៗ

រឿនៈ ចា៎ អត់មានទឹងទេ ហើយចុះខ្ញុំទៅផ្សារទៅអីហ្នឹង ទៅបុណ្យទៅអីហ្នឹងទៅជាមួយគ្នាហ្នឹង ទៅកឋិនអី ជួប លែងទឹងអស់ហើយ ចេះតែរាប់ដូចបងប្អូនហ្នឹង ។

រឿនៈ គាត់និយាយហ្នឹង ដូចថា សន្តមអន្ទាក់អីអញ្ចឹង ។

រឿនៈ ចា៎ គាត់មិនមែនចង់ធ្វើអញ្ចឹងទេគេដឹកនាំ ។

រឿនៈ អោយចប់ទៅ ខ្ញុំមិនចង់សងសឹកទេ ។

រឿនៈ អត់ទេ លែង សងសឹកហើយ ចប់តែម្តង ចប់ត្រឹមហ្នឹង ។

រឿនៈ អត់ ។

រឿនៈ វាមិនសូវដែលបានស្តាប់វិទ្យុ បន្តិចទៅនេះ បន្តិចទៅនោះ ។

រឿនៈ ចង់អោយនៅចំរុះគ្នា ។

រឿនៈ ឈប់អោយបែកទៅ ពិបាកណាស់ ។

រឿនៈ ចា៎ ។

រឿនៈ ចា៎ យើងពិបាកណាស់ អាបែកគ្នាអញ្ចឹង វាពិបាក ពិបាករស់នៅ ។

រឿនៈ នៅតែចងកំហឹងគ្នា តែបែកអញ្ចឹង នៅតែចងកំហឹងគ្នា ។

រឿនៈ ចង់អោយតែនៅផ្លូវធ្លង់ទេ សុខសាន្តនឹងគ្នា ឪមួយ ម៉ែមួយអញ្ចឹង ។

រឿនៈ ប្រាប់តែកូន ។

រឿនៈ ប្រាប់តែក្មួយៗៗ ហ្នឹង វានៅ អត់ដូចកូនឯងទេ អត់បានមួយមៅ៉ងទេ តែប៉ុន្មានទាទីគេ យកបាត់ហើយ អាងឹក់ងរ ដាក់ម៉ែច្រើន ។

រឿនៈ ចា៎ អត់បានទេ ។

រឿនៈ ប្រាប់ថា កូនឯងមិនកើតទាន់ជំនាន់ប៉ុល ពត កូនឯងមិនដឹងរបៀបរបប ជំនាន់ប៉ុល ពត ទេ ប៉ុល ពត លំបាកណាស់ណាកូន អត់ហូបម៉ែ ហូបត្រាវ បបរត្រាវរីង ផាប់ក៏មានដែរ ត្នោតធំតាឡើងបន្ទេះ យកមកចិតរំងាស់ យកមកហូបក៏មានដែរ ដាល់ដ្តិល យកមក អោយ កូនហូប ។

រឿនៈ ហើយត្រាវពីដើម ត្រាវព្រៃអោះ ហើយយកមកដាក់លីង លីងហើយ បបរជាមួយអង្ករ មួយគ្រាប់ មួយគ្រាប់ វានៅរមាស់ ហូបហើយ រមាស់ក រីងអណ្តាតអស់ បៀមអំបិល ហើយអត់ដឹងទេ ប្រាប់កូនឯង ហើយសំដី ក្រម៉ក់ក្រម៉ូវប្រើមិនបាន អញ្ចឹងកូនឯង

អត់បានមួយម៉ោងទេ កុំធ្វើអញ្ចឹង ម៉ែពិបាកឆ្ងងកាត់អាំ នៅមួយៗហ្នឹង មិនដឹងកើតប៉ុន្មានដងទេ កូនឯងឥលូវនេះ អត់ដឹងទេ ។

រឿនៈ ប្រាប់វាអញ្ចឹង ។

រឿនៈ ប្រាប់អោយ កុំអោយរឿងហ្នឹងកើត ។

រឿនៈ ប្រាប់អោយវាដឹង ដឹងខ្វះ ពន្យល់អោយវាដឹងខ្វះ ហើយវានៅង៉ក់ ងរ ចេះតែ ប្រដៅវា កុំចិត្តច្រើន មានអី ហូបហ្នឹងទៅ ។

រឿនៈ ចប់ហើយ ។

រឿនៈ ដូចសព្វថ្ងៃ ចិត្តខ្ញុំចង់អោយរួបរួមគ្នា ឪមួយ ម៉ែមួយអញ្ចឹងអណា កុំអោយបែកខ្ញែកគ្នា មួយនៅនេះ មួយនៅនោះ ខ្លាចគេសងសឹក ខ្លាចគំនុំទៀត ។

រឿនៈ ក៏លែងទឹងដែរ ឈប់ទឹងហើយ ឥលូវ ឈប់ទឹងហើយ មិនដឹងធ្វើម៉េចបើសគ្គមពីមុន វាហួសហើយ ឥលូវវាមកឥលូវ យើងទៅឃើញល្អកល្អើននឹងគ្នាសប្បាយជឿនលឿន ។

រឿនៈ ប្រាប់ ។

រឿនៈ ថាធ្វើម៉េចពីមុន ។

រឿនៈ ចាំ ឥលូវគាត់សុំសីល ទៅបុណ្យទៅអី ជួបគ្នានៅហ្នឹង ជួបគ្នាអីអញ្ចឹង គាត់មកឱប ខ្ញុំអោបគាត់អញ្ចឹងទៅណា ។

រឿនៈ ចាំ មិត្តសៀនហ្នឹង ខ្ញុំជួបនៅនឹងផ្សារទេ ហើយគារ៉េមហ្នឹងជួបនៅផ្សារទេ គេគេចមុខដែរណា ប៉ុនតែខ្ញុំសួរ គេគេចមុខខ្ញុំហ្នឹងអាំ ខ្លាច ហើយឥលូវកូនគាត់ ប្អូន ប្រាំនាក់អើយនៅក្នុងភូមិហ្នឹង ប្រធានក្រុម ប្រធានកង សុទ្ធតែបងប្អូនរាប់អានគ្នារាល់ថ្ងៃ ។

រឿនៈ អឺ ស្រាច់តែរដ្ឋអំណាច ស្រាច់តែរដ្ឋអំណាច ។

រឿនៈ មិនដឹងធ្វើម៉េចទេ ស្រេចតែលើរដ្ឋអំណាច មឹងសួរដឹងដែរហ្នឹង ឥលូវ សប្បាយអាមើលបរទេសនៅឯណា បារាំងនៅឯណា មកជួបជុំហើយមុនហ៊ានដើរអញ្ចឹង អត់ហ៊ានដើរទេ ។

រឿនៈ ប្រទេសណាក៏មក ឃើញអញ្ចឹងសប្បាយ អញ្ចឹង ស្អាតទៀតចេះខ្មែរទេ?

រឿនៈ អត់បានទេ តែមកអង្គុយអញ្ចឹង ដើរអញ្ចឹងបាននោះ អត់បានទេ ពីមុន ឥលូវដើរដល់ណាក៏អត់អីដែរ អោយតែមានលុយដើរ ឥលូវ បារាំង អង្គការអី ជិះកង ។

រឿនៈ គ្រាន់បើបានច្រើនធូរ បានច្រើន ធូរ បាន ៧០ ភាគរយ ហើយចាំមើលគេមកជួប

ទៀតហើយ ហើយអាសារហ្នឹង អត់បានថ្នាំ ខ្ញុំអស់ថ្នាំលេប ។

រឿនៈ ចា៎ ។

រឿនៈ ត្រូវ លេបថ្នាំហ្នឹង ត្រូវតើ កាលពីមុន ខ្ញុំអើយ ឈឺអស់ហើយ ឥលូវសំរាន្តបាន ហូប បាន ស្គម ឥលូវហ្នឹងមានសាច់បន្តិច ។

រឿនៈ ចា៎ ។